# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# វិស័យបរិស្ថាន និងស្ថាប័នគ្រប់គ្រងធនធានធម្មជាតិ
# នៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩


| | |
|---|---|
| តាក់តែងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ កញ្ញា **ស្រេន សុធារី** | លោក **យូ តូនី** |
| កញ្ញា **និត សំអូន** | |
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | ឆ្នាំចូលសិក្សា ២០១៥ |
| ជំនាន់ទី១២ | ឆ្នាំសរសេរបាយការណ៍ ២០១៩ |

# **អារម្ភកថា**

យើងខ្ញុំបានស្រាវជ្រាវ និងចងក្រងឯកសារនេះឡើង ក្នុងគោលបំណង ដើម្បីឆ្លើយតបទៅនឹងការចាំបាច់ដែលសាកលវិទ្យាល័យតម្រូវឱ្យ យើងខ្ញុំ សរសេរសារណា ឬរបាយការណ៍កម្មសិក្សា ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ឆ្នាំសិក្សា ២០១៨-២០១៩ របស់យើងខ្ញុំ និងមានបំណងរួមចំណែកកសាងឯកសារសម្រាប់ការសិក្សាស្រាវជ្រាវ និងស្វែងយល់សម្រាប់មិត្តអ្នកអាន និងសម្រាប់ទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយៗទៀត។

សារណាដែលស្តីអំពី **"វិស័យបរិស្ថាន និងស្ថាប័នគ្រប់គ្រងធនធានធម្មជាតិនៅព្រះរាជាណាចក្រកម្ពុជា"** ត្រូវបានរៀបចំតាក់តែងឡើង ដោយធ្វើការសិក្សាវិភាគលើសារៈសំខាន់ និងភាពចាំបាច់នៃការការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបង្ហាញអំពីអង្គការជាតិ និងអន្តរជាតិ ដែលមានតួនាទី ចូលរួមចំណែកក្នុងការអភិរក្ស ធនធានធម្មជាតិ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះនឹងជួយដល់អ្នកអាន អ្នកស្រាវជ្រាវដែលចង់ទទួលបាននូវចំណេះដឹង និងយល់ឱ្យច្បាស់ទៅនឹងបរិស្ថាន ធម្មជាតិ នៅក្នុងប្រទេសយើង។ ប៉ុន្តែយើងខ្ញុំក៏អាចបង្កើតកំហុសឆ្គងលើការសរសេរអត្ថាធិប្បាយ ឬការវិភាគខ្លះៗ ជាក់ជាមិនខាន។ ដូច្នេះ យើងខ្ញុំរង់ចាំដោយក្តីសោមនស្សរីករាយដើម្បីទទួលនូវមតិរិះគន់កែលម្អពីលោក-លោកស្រីសាស្ត្រាចារ្យ និងមិត្តអ្នកសិក្សាស្រាវជ្រាវទាំងអស់ និងព្រមទាំងប្អូនៗជំនាន់ក្រោយទៀត ក្នុងការធ្វើឱ្យសារណាមួយនេះកាន់តែមានលក្ខណៈល្អប្រសើរឡើងថែមទៀត។

យើងខ្ញុំសូមប្រសិទ្ធិពរដល់លោក-លោកស្រី សាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ សូមឱ្យជួបប្រទះតែ នឹងសេចក្តីសុខគ្រប់ប្រការ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ក.ស្រែន សុធារី ក.និត សំអូន** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់១២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ**

**លោកឪពុក អ្នកម្តាយ** ជាទីស្រឡាញ់ ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សា ទូន្មាន ប្រៀនប្រដៅ ផ្តល់កម្លាំងចិត្ត និងជួយទំនុកបំរុងកូនបានសិក្សាតាំងពីថ្នាក់បឋមសិក្សា រហូតទទួលបានជោគជ័យថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។ កូនសូមដឹងគុណនិងមិនបំភ្លេចបាននូវគុណណូបការៈរបស់លោកអ្នកមានគុណទាំងពីរ។

សូមថ្លែងអំណរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស និងលោកព្រឹទ្ធបុរសរង ព្រមទាំងលោកគ្រូ-អ្នកគ្រូ** ជាសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់ បង្ហាញ និងផ្តល់ពុទ្ធិដ៏ល្អប្រពៃ ជាពិសេសក្នុងជំនាញរដ្ឋបាលសាធារណៈដល់យើងខ្ញុំ។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យ **យូ តូនី** ដែលជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណានេះ ដោយលោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃ និងបានផ្តល់ដំបូន្មានល្អៗជួយឱ្យយើងខ្ញុំអាចសម្រេចកិច្ចការនេះ ប្រកបដោយជោគជ័យ។

ជាទីបញ្ចប់ នាងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ ជួយតាមថែរក្សាអស់លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់និងសូមឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម**..........01

## ជំពូកទី១

## ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ

ផ្នែកទី១: ស្ថាប័នជាតិ.......... ០៣

១.១. ក្រសួងបរិស្ថាន ..........០៣

១.២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ .......... ១២

១.៣. ក្រសួងរ៉ែ និងថាមពល .......... ១៤

ផ្នែកទី២: ស្ថាប័នគាំពារបរិស្ថាន និងធនធានធម្មជាតិ.......... ១៦

២.១. ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព.......... ១៦

២.២. អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្ស និងធនធានធម្មជាតិ.......... ១៨

## ជំពូកទី២

## សកម្មភាពផ្សេងៗក្នុងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ

ផ្នែកទី១: ការគាំពារបរិស្ថាន ..........២០

១.១. ការគ្រប់គ្រងគុណភាពខ្យល់ និងសម្លេង.......... ២០

១.២. ការគ្រប់គ្រងគុណភាពទឹក .......... ២០

១.៣. ការគ្រប់គ្រងសំណល់រឹង .......... ២១

១.៤. ការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ ..........២២

១.៥. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន..........២៣

ផ្នែកទី២: ការការពារ និងអភិរក្សធនធានធម្មជាតិ .......... ២៣

២.១. ការអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ ..........២៣

២.២. ការអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប.......... ២៤

២.៣. ការអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប .......... ២៥

២.៤. ការអភិរក្សតំបន់ដីសើមទឹកសាប.......... ២៥

២.៥. ការអភិរក្សសមុទ្រនិងតំបន់ឆ្នេរ .......... ២៦

## ជំពូកទី៣
## ផែនការអនាគតក្នុងការអភិវឌ្ឍបរិស្ថាន និងធនធានធម្មជាតិ

ផ្នែកទី១: ការកសាងសមត្ថភាព និងការយល់ដឹងរបស់សាធារណជនលើវិស័យបរិស្ថាន..២៧
១.១. ពង្រឹងសមត្ថភាពមន្ត្រី....................................................................................២៧
១.២. ការបណ្តុះបណ្តាលប្រជាពលរដ្ឋ និងយុវជនឱ្យយល់ដឹងពីការការពារបរិស្ថាន....... ២៨
ផ្នែកទី២: ការទប់ស្កាត់ និងផ្សព្វផ្សាយពីបញ្ហាបរិស្ថាននិងធនធានធម្មជាតិ..................២៩
២.១. ការទប់ស្កាត់ការបំពុលបរិស្ថាន និងធនធានធម្មជាតិ.......................................... ២៩
២.២. ការផ្សព្វផ្សាយពីបញ្ហាបរិស្ថាន និងធនធានធម្មជាតិ ...........................................៣០
**សេចក្តីសន្និដ្ឋាន**..........................................................................................................៣១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ក្នុងការគ្រប់គ្រងប្រទេសកម្ពុជាកន្លងមក ឆ្លងកាត់ស្ថានភាពដ៏លំបាកជាច្រើនទម្រាំឈានមកដល់ការរីកចម្រើនដូចសព្វថ្ងៃ ដែលជាប្រទេសប្រជាធិបតេយ្យ សន្តិភាព ស្ថិរភាពនយោបាយ សេរីភាព សណ្តាប់ធ្នាប់សង្គម សេដ្ឋកិច្ចកាន់តែរីកចម្រើន និងភាពក្រីក្រកាន់តែកាត់បន្ថយបន្តបន្ទាប់។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រទេសស្ទើរគ្រប់វិស័យទាំងអស់ ក្នុងនោះវិស័យបរិស្ថាន និងធនធានធម្មជាតិជាស្នូលនៃ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។

ស្របពេលជាមួយគ្នា នឹងការតែងតាំងរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី១ នៃរដ្ឋសភាឆ្នាំ១៩៩៣ «រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន» ក៏ត្រូវបានបង្កើតឡើង ដើម្បីទទួលបន្ទុកការងារគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ។ ដោយហេតុថា វិសាលភាពការងារគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិមានទំហំធំ ហើយទាមទារឱ្យមានការគ្រប់គ្រង និងការចូលរួមជាមួយដៃគូសហការជាច្រើន រាជរដ្ឋាភិបាលបានសម្រេចដំឡើង «រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន» ឱ្យទៅជា «ក្រសួងបរិស្ថាន» ហើយបានដាក់ដំណើរការចាប់ពីឆ្នាំ១៩៩៧មកម្ល៉េះ។ បច្ចុប្បន្នក្រសួងបរិស្ថានបាន និងកំពុងរួមចំណែកអនុវត្តឱ្យបានជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤គោលនយោបាយ និងមតិណែនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដែលមានគោលដៅធានាឱ្យតុល្យភាពរវាង ការអភិរក្ស និងការអភិវឌ្ឍ ស្របតាមទស្សនាទាន ការអភិវឌ្ឍដោយចីរភាពដែលតម្រូវឱ្យមានតុល្យភាពរវាងបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ តែទោះជាយ៉ាងណាក៏បញ្ហានៃការគ្រប់គ្រងធនធានធម្មជាតិក៏នៅតែកើតមានឡើងដោយសារកង្វះខាតការអប់រំដល់ប្រជាពលរដ្ឋធ្វើឱ្យមានការកាប់បំផ្លាញព្រៃឈើ និងបំផ្លាញធនធានធម្មជាតិជាដើម។

ជាមធ្យោបាយក្រសួងបរិស្ថានបានរៀបចំនូវ គោលដៅយុទ្ធសាស្ត្រ និងទិសដៅសកម្មភាពដោយបានកំណត់ក្នុងសសរស្តម្ភទាំងបួនគឺ ការធ្វើទំនើបកម្មស្ថាប័ន កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព។ ក្រសួងបានខិតខំឈរលើសសរស្តម្ភទាំងបួនសំដៅធានាសម្រេចឱ្យបានជោគជ័យក្នុងការកសាងសង្គមកម្ពុជា ដែលមានបរិស្ថានល្អស្អាត តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី ដើម្បីជាឧត្តមប្រយោជន៍ និងភាពសុខដុមរមនា សម្រាប់ប្រជាជនគ្រប់ជំនាន់ ។

ដោយបុព្វហេតុទាំងនេះហើយ ទើបបណ្តាលឱ្យយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ "**វិស័យបរិស្ថាន និងស្ថាប័នគ្រប់គ្រងធនធានធម្មជាតិនៅព្រះរាជាណាចក្រកម្ពុជា**"។ ប្រធានបទនេះនឹងធ្វើការលើកឡើងដោយផ្អែកឡើងតាម ភូមិសាស្ត្រ តំបន់អេកូឡូស៊ីនិងតំបន់អភិរក្សផ្សេងៗទៀតរបស់ក្រសួងបរិស្ថាននិងដៃគូដែលពាក់ព័ន្ធនានា។

តើរាល់ស្ថាប័នទាំងអស់ធ្វើការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិតាមវិធីណា?

ជាការពិតណាស់ការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិគឺមានការទាក់ទងទៅនឹងជីវភាព សុខភាពរបស់ប្រជាពលរដ្ឋ។ ជាពិសេសដើម្បីអនុវត្តសកម្មភាពដើម្បីជំរុញក្នុងការអភិរក្សធនធានធម្មជាតិ។

ដើម្បីឆ្លើយតប ទៅនឹងសំណួរគតិយុត្តខាងលើ ប្រធានបទ "**វិស័យបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិនៅព្រះរាជាណាចក្រកម្ពុជា**" នេះនឹងត្រូវធ្វើការបកស្រាយតាមរយៈការ បែងចែកជាបីជំពូកធំៗគឺ៖

**ជំពូកទី១ ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ**

**ជំពូកទី២ សកម្មភាពផ្សេងៗក្នុងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ**

**ជំពូកទី៣ ផែនការអនាគតក្នុងការអភិវឌ្ឍបរិស្ថាន និងធនធានធម្មជាតិ**

# ជំពូកទី១

# ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ

បរិស្ថាន និងធនធានធម្មជាតិត្រូវបានយកចិត្តទុកដាក់ជាខ្លាំងពីសំណាក់រាជរដ្ឋាភិបាល ដៃគូសហការ អង្គការជាតិ និងអន្តរជាតិនានា។ យ៉ាងណាមិញក្រសួង និងដៃគូសហការនានា បានខិតខំបង្កើតគោលនយោបាយ ការផ្សព្វផ្សាយអំពីបរិស្ថានជូនដល់ប្រជាពលរដ្ឋ ដើម្បីបញ្ជ្រាបក្នុងការកាត់បន្ថយសកម្មភាពប៉ះពាល់បរិស្ថាន និងការកាប់បំផ្លាញធនធានធម្មជាតិជាដើម។ ក្នុងជំពូកនេះយើងខ្ញុំ និងបង្ហាញពីស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិះ

## ផ្នែកទី១ : ស្ថាប័នជាតិ

### ១.១. ក្រសួងបរិស្ថាន

ក្រសួងបរិស្ថានត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[1]

បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ស្ថាប័នជាបន្តបន្ទាប់ ក្រសួងបរិស្ថានបានរៀបចំឱ្យមាន រចនាសម្ព័ន្ធគ្រប់គ្រងរួមមាន អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពជាយន្តការសម្របសម្រួល ការរៀបចំគោលនយោបាយផែនការ និងយុទ្ធសាស្ត្រ អគ្គនាយកដ្ឋានគាំពារបរិស្ថានជាអង្គភាពបច្ចេកទេសគ្រប់គ្រងសំណល់រឹង រាវ ការបំពុលបរិស្ថានគ្រប់ប្រភេទ និងសារធាតុគ្រោះថ្នាក់ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិជាអង្គភាពបច្ចេកទេសគ្រប់គ្រងតំបន់ការពារធម្មជាតិ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ជាអង្គភាពបច្ចេកទេសគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីលើកកម្ពស់ជីវភាពសហគមន៍ ការអភិរក្សតំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ និងការអភិវឌ្ឍគោលដៅទេសចរណ៍ធម្មជាតិ អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថានជាអង្គភាពទទួលបន្ទុកការបញ្ជ្រាបការយល់ដឹងជាសាធារណៈ អំពីបរិស្ថាន និងធនធានធម្មជាតិដល់ស្រទាប់មហាជនគ្រប់មជ្ឈដ្ឋានទាំងក្នុងប្រព័ន្ធអប់រំនិងក្រៅប្រព័ន្ធ និងអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុជាអង្គភាពទ្រទ្រង់ និងផ្គត់ផ្គង់ដល់អង្គភាពជំនាញក្រោមឱវាទក្រសួង ដើម្បីធានាដល់ដំណើរការនិងប្រសិទ្ធភាពការងាររបស់ក្រសួង។

ម្យ៉ាងវិញទៀត ដោយផ្អែកលើកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ក្រសួងបរិស្ថានបានកំណត់យកការងារអាទិភាព ដែលត្រូវអនុវត្តឱ្យបានជោគជ័យ ដូចជាកិច្ចគាំពារជីវភាពមន្ត្រីរាជការ ការពង្រឹងស្មារតីសាមគ្គីភាព ការធ្វើទំនើបកម្មស្ថាប័នកិច្ចគាំពារបរិស្ថាន ការការពារធនធានធម្មជាតិ ការអភិរក្សជីវចម្រុះ និងការពង្រឹងកិច្ច

[1]មាត្រា២ អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

សហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ។ ក្នុងក្របខ័ណ្ឌនៃកិច្ចគាំពារជីវភាពមន្ត្រីរាជការ ដើម្បីពង្រឹងស្មារតីសាមគ្គីភាព ភាពជឿទុកចិត្តគ្នាឯកភាពផ្ទៃក្នុងនិងភាពម្ចាស់ការលើខ្លួនឯង យើងបានអនុវត្តនូវគោលនយោបាយគាំពារប្រមាណ១៥សកម្មភាព ដោយផ្អែកលើលទ្ធភាពជាក់ស្តែងរបស់ក្រសួងដែលមានជាអាទិ៍ៈ ការជួយឧបត្ថម្ភ និងផ្តត់ផ្គង់ដល់មន្ត្រីពេលសម្រាលបុត្រ រៀបការ មរណភាព អាហារថ្ងៃត្រង់ ការផ្តល់របបប្រេង ការចែកប្រាក់រង្វាន់ ជួយបញ្ចុះតម្លៃការពិនិត្យព្យាបាលជម្ងឺ និងការយកចិត្តទុកដាក់ចំពោះមន្ត្រីចូលនិវត្តន៍។ល។

ក្រសួងបរិស្ថានមានមុខងារ និងភារកិច្ចដូចខាងក្រោមៈ

- រៀបចំទស្សនវិស័យ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ព្រមទាំងកំណត់អាទិភាពអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- តាក់តែងនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅដោយចីរភាព
- សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ផែនការ និងកម្មវិធីនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន
- ផ្តល់យោបល់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានា ការអភិរក្ស ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- គ្រប់គ្រងទិន្នន័យបរិស្ថាននិងដឹកនាំសម្របសម្រួលការងារអប់រំនិងការផ្សព្វផ្សាយបរិស្ថានព្រមទាំងចាត់ចែងពិធីសំខាន់ៗទាក់ទងនឹងវិស័យបរិស្ថាន
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅដោយចីរភាព តាមរយៈការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពបង្កើនការយល់ដឹងនានា
- លើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅដោយចីរភាព តាមរយៈការពិគ្រោះយោបល់ជាសាធារណៈនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចនានា
- ផលិត និងផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពទាក់ទងនឹងកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិជូនសាធារណជន
- គ្រប់គ្រងនិងសម្របសម្រួលកិច្ចគាំពារបរិស្ថាន រួមមាន ការគ្រប់គ្រងគុណភាពទឹក ខ្យល់ និងដី ការគ្រប់គ្រងសំឡេងនិងរំញ័រ និងការគ្រប់គ្រងការបំភាយកាំរស្មី វិទ្យុសកម្ម និងអេឡិចត្រូម៉ាញ៉េទិក
- រៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន

- គ្រប់គ្រងនិងសម្របសម្រួលការងារការពារនិងអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- ប្រមូល វិភាគ និងគ្រប់គ្រងទិន្នន័យបរិស្ថាននិងធនធានធម្មជាតិ
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជាឱ្យបានទៀងទាត់
- លើកសំណើជូនរាជរដ្ឋាភិបាលអំពីការចូលរួមក្នុងកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានា ដែលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាពព្រមទាំងអនុវត្តកិច្ចការជំនាញពាក់ព័ន្ធ សម្រាប់ជាមូលដ្ឋានជូនរាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ច និងការទទួលខុសត្រូវនៅក្រោមកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារទាំងនោះ
- ជំរុញនិងលើកទឹកចិត្តឱ្យមានការវិនិយោគក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅដោយចីរភាព
- កៀរគរនិងគ្រប់គ្រងធនធានសម្រាប់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងនិរន្តរភាពនិងការរស់នៅដោយចីរភាព
- សហការជាមួយបណ្តាប្រទេសនៅក្នុងតំបន់និងពិភពលោក អង្គការជាតិ អង្គការអន្តរជាតិ និងសហគមន៍មូលដ្ឋាន ដើម្បីធានាឱ្យមានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅដោយចីរភាព
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។[2]

ក្រសួងបរិស្ថានមានអគ្គនាយកដ្ឋានចំនួន៥ ដូចជា អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន អគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។ នៅក្នុងអគ្គនាយកដ្ឋាននីមួយៗមានតួនាទីភារកិច្ចខុសៗគ្នា និងមាននាយកដ្ឋានចំណុះដូចជា៖

➢ អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន

អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថានមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការនិងកម្មវិធីនានាពាក់ព័ន្ធការអប់រំនិងផ្សព្វផ្សាយព័ត៌មានបរិស្ថាន
- គ្រប់គ្រងកិច្ចការនានា ដែលទាក់ទងនឹងរដ្ឋបាល ផែនការ គណនេយ្យ ហិរញ្ញវត្ថុនិងមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌនៃអគ្គនាយកដ្ឋាន

[2] មាត្រា៣ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

- ប្រមូល វិភាគ ចងក្រង និងគ្រប់គ្រងព័ត៌មាននិងទិន្នន័យបរិស្ថាននិងធនធានធម្មជាតិ រួមទាំងប្រព័ន្ធទិន្នន័យឯកទេស
- ផលិតនិងផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅដោយចីរភាព
- រៀបចំរបាយការណ៍ជាទៀងទាត់ស្តីពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា
- លើកកម្ពស់ការអប់រំ និងការយល់ដឹងអំពីបរិស្ថានដល់សាធារណជន
- រៀបចំ និងចាត់ចែងពិធីនានាជាសាធារណៈនិងសកម្មភាពផ្សព្វផ្សាយបរិស្ថាន
- លើកទឹកចិត្តឱ្យមានសកម្មភាព ដែលមានមេត្រីភាពជាមួយបរិស្ថាន
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរិស្ថាន
- សម្របសម្រួលជាមួយអង្គភាពនានាក្រោមឱវាទក្រសួង ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនិងបង្កើនប្រសិទ្ធភាពការងារគ្រប់គ្រងទិន្នន័យបរិស្ថាន និងការងារអប់រំ និងផ្សព្វផ្សាយបរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថានមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ
- នាយកដ្ឋានអប់រំបរិស្ថាន
- នាយកដ្ឋានព័ត៌មាននិងផ្សព្វផ្សាយបរិស្ថាន
- នាយកដ្ឋានរង្វាន់និងលើកទឹកចិត្ត។[3]

➢ អគ្គនាយកដ្ឋានគាំពារបរិស្ថាន

អគ្គនាយកដ្ឋានគាំពារបរិស្ថានមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រជាតិពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន
- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ស្តង់ដារគុណភាពបរិស្ថាននិងស្តង់ដារនៃការបញ្ចេញសំណល់ ឬសារធាតុបំពុល
- គ្រប់គ្រងគុណភាពទឹក ខ្យល់ និងដី គ្រប់គ្រងសំឡេងនិងរំញ័រ និងគ្រប់គ្រងការបំភាយសារធាតុគ្រោះថ្នាក់រួមទាំងកាំរស្មី វិទ្យុសកម្ម និងអេឡិចត្រូម៉ាញ៉េទិក

[3] មាត្រា៥ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

- រៀបចំ និងអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការត្រួតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថានលើរាល់សំណើនិងគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ គណនេយ្យ ហិរញ្ញវត្ថុ និងមន្ត្រីរាជការ និងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌របស់អគ្គនាយកដ្ឋាន
- ប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យប្រភពបំពុលគុណភាពបរិស្ថាន និងទិន្នន័យសំណល់ និងសារធាតុគ្រោះថ្នាក់បរិស្ថាន
- គ្រប់គ្រងវដ្តនៃសារធាតុបំពុលខ្យល់ សំណល់រាវ សំណល់រឹង និងសំណល់គ្រោះថ្នាក់
- សិក្សា ស្រាវជ្រាវ និងផ្តល់ការណែនាំអំពីបច្ចេកវិទ្យាសមស្របសម្រាប់ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសារធាតុគ្រោះថ្នាក់បរិស្ថានប្រកបដោយសុវត្ថិភាព
- សិក្សា ស្រាវជ្រាវ និងវាយតម្លៃអំពីការសាយភាយជាតិពុលពីសំណល់និងសារធាតុគ្រោះថ្នាក់បរិស្ថានចូលក្នុងបរិស្ថាន កម្រិតនៃការបំពុលបរិស្ថាន និងផលប៉ះពាល់ទៅលើសុខភាព
- អង្កេត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពគុណភាពបរិស្ថាន ទឹក ខ្យល់ ដី និងផ្តល់ការណែនាំបច្ចេកទេសដល់អង្គភាពជំនាញនៅថ្នាក់ក្រោមជាតិ
- អង្កេត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារគ្រប់គ្រងសំណល់រឹងរាវ និងផ្តល់ការណែនាំបច្ចេកទេសដល់អង្គភាពជំនាញនៅថ្នាក់ក្រោមជាតិ
- អនុវត្តការផ្តល់សេវាកម្មសាធារណៈពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាតាមរយៈការចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើទីតាំង ឬ មធ្យោបាយនៃផលិតកម្ម អាជីវកម្ម ឬ សេវាកម្ម ដែលពាក់ព័ន្ធ នឹងការនាំចូល ការនាំចេញ ការឆ្លងកាត់ ការបង្កើត ការផលិត ការប្រើប្រាស់ ការកែច្នៃ ការធ្វើប្រព្រឹត្តកម្ម និងការបោះបង់ចោល ឬ ការបញ្ចេញចោលសំណល់និងសារធាតុគ្រោះថ្នាក់បរិស្ថាន
- ត្រួតពិនិត្យ និងផ្តល់យោបល់លើដំណើរការទាំងមូលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការពិនិត្យតាមដានផែនការគ្រប់គ្រងបរិស្ថាន
- ផ្តល់យោបល់ និងសម្របសម្រួលជាមួយស្ថាប័ន ឬ អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការទប់ស្កាត់ ឬ លុបបំបាត់ការបំពុលបរិស្ថាន ការស្តារគុណភាពបរិស្ថានឡើងវិញនិងចូលរួមវាយតម្លៃអំពីការខូចខាត ឬ ផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីការបំពុលបរិស្ថាន

- រៀបចំផែនការត្រៀមបង្ការសម្រាប់ឆ្លើយតបបន្ទាន់លើករណីឧបទ្ទវហេតុនៃគ្រោះបំពុលបរិស្ថានផ្សេងៗ
- ផ្តល់សេវាកម្មមន្ទីរពិសោធន៍សម្រាប់គាំទ្រដល់ការងារកិច្ចគាំពារបរិស្ថាន និងសម្រាប់សាធារណជនទូទៅ
- បំពេញកិច្ចការជំនាញតាមកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានា ទាំងថ្នាក់តំបន់ និងថ្នាក់ពិភពលោក ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ដែលកម្ពុជាជាសមាជិក ហើយដែលក្រសួងបរិស្ថានជាស្ថាប័នបង្គោលជាតិ
- រៀបចំរបាយការណ៍ជាតិស្តីពីស្ថានភាពគុណភាពបរិស្ថាន ឬស្ថានភាពនៃការបំពុលបរិស្ថានជាពិសេសនៅតាមតំបន់ ដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍ និងងាយរងការបំពុលបរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗ ទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានគាំពារបរិស្ថានមាននាយកដ្ឋានចំណុះដូចខាងក្រោមៈ

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់និងសំឡេង
- នាយកដ្ឋានគ្រប់គ្រងគុណភាពទឹក
- នាយកដ្ឋានគ្រប់គ្រងសំណង់រឹង
- នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់
- នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់
- មន្ទីរពិសោធន៍។[4]

➢ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ

- រៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- អប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយ អំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ

[4] មាត្រា១១ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ គណនេយ្យ និងមន្ត្រីរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌របស់អគ្គនាយកដ្ឋាន
- ដឹកនាំការគ្រប់គ្រងនិងការអភិរក្សជីវៈចម្រុះនៅក្នុងតំបន់ការពារធម្មជាតិ
- ធានាការគ្រប់គ្រង និងការប្រើប្រាស់ធនធានក្នុងតំបន់ការពារធម្មជាតិឱ្យមាននិរន្តរភាព
- ដឹកនាំការសិក្សា ស្រាវជ្រាវ និងការរៀបចំទិន្នន័យប្រភេទសត្វ និងរុក្ខជាតិដែលកម្រ ងាយរងគ្រោះ កំពុងរងគ្រោះ និងជិតផុតពូជនៅក្នុងតំបន់ការពារធម្មជាតិ
- ចូលរួមការអនុវត្តសកម្មភាពថែរក្សាប្រពៃណី ទំនៀមទម្លាប់ និងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ តាមរយៈការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ រួមទាំងសកម្មភាពទេសចរណ៍ធម្មជាតិ
- គ្រប់គ្រងតំបន់ដីសើមនិងធនធានទឹកសាប
- គ្រប់គ្រងធនធានសមុទ្រនិងតំបន់ឆ្នេរ
- ចូលរួមគ្រប់គ្រង និងអភិរក្សតំបន់បេតិកភណ្ឌនៅក្នុងតំបន់ការពារធម្មជាតិ
- ពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ
- បំពេញកិច្ចការជំនាញតាមកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានាទាំងថ្នាក់តំបន់ និងថ្នាក់ពិភពលោក ពាក់ព័ន្ធនឹងកិច្ចការពារ និងអភិរក្សធម្មជាតិដែលកម្ពុជាជាសមាជិក
- សិក្សា និងកំណត់តំបន់គ្រប់គ្រងនីមួយៗ សម្រាប់ការអភិរក្សនិងការអភិវឌ្ឍ
- ធ្វើការស្តារ ដាំដុះព្រៃឈើនៅតំបន់រេចរិល និងអភិរក្សព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិ ដើម្បីរួមចំណែកកាត់បន្ថយការរេចរិល និងការបាត់បង់ព្រៃឈើ ព្រមទាំងកាត់បន្ថយការប្រែប្រួលអាកាសធាតុ
- ស្វែងរកការគាំទ្រផ្នែកបច្ចេកទេសនិងកៀរគរធនធានហិរញ្ញវត្ថុ ទាំងកម្រិតជាតិ និងអន្តរជាតិ សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

_ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
_ នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ
_ នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប
_ នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
_ នាយកដ្ឋានអភិរក្សដីសើមទឹកសាប
_ នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ
_ នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់។[5]

➢ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន

អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

_ រៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន និងសហគមន៍តំបន់ការពារធម្មជាតិ
_ រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន និងសហគមន៍តំបន់ការពារធម្មជាតិ
_ គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ គណនេយ្យ និងមន្ត្រីរបស់អគ្គនាយកដ្ឋាន
_ ដឹកនាំការសិក្សាស្រាវជ្រាវ ការរៀបចំបង្កើត និងការគ្រប់គ្រងសហគមន៍មូលដ្ឋាន
_ ដឹកនាំការសិក្សាស្រាវជ្រាវ ការរៀបចំបង្កើត និងការគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ
_ សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពជំនាញពាក់ព័ន្ធ និងវិស័យឯកជនក្នុងការគ្រប់គ្រងគម្រោងវិនិយោគទេសចរណ៍ធម្មជាតិ
_ សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពជំនាញពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ក្នុងការលើកកម្ពស់សកម្មភាពទេសចរណ៍ធម្មជាតិនៅក្នុងសហគមន៍មូលដ្ឋាន និងសហគមន៍តំបន់ការពារធម្មជាតិ
_ អប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយ អំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍសហគមន៍មូលដ្ឋាននិងសហគមន៍តំបន់ការពារធម្មជាតិ
_ សម្របសម្រួល និងដឹកនាំអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងសហគមន៍តំបន់ការពារធម្មជាតិ រួមទាំងការថែរក្សាប្រពៃណី និងទំនៀមទម្លាប់របស់សហគមន៍ជនជាតិដើមភាគតិច
_ ស្វែងរកការគាំទ្រផ្នែកបច្ចេកទេស និងកៀរគរធនធានហិរញ្ញវត្ថុ ទាំងកម្រិតជាតិ និងអន្តរជាតិ សម្រាប់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន និងការគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ

[5]មាត្រា២០ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

_ បំពេញកិច្ចការជំនាញតាមកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានា ទាំងថ្នាក់តំបន់ និងថ្នាក់ពិភពលោក ពាក់ព័ន្ធនឹងសហគមន៍មូលដ្ឋាន ទេសចរណ៍ធម្មជាតិ និងកិច្ចការពារ និងការអភិរក្សតំបន់បេតិកភណ្ឌធម្មជាតិដែលកម្ពុជាជាសមាជិក

_ រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ

_ ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

_ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ

_ នាយកដ្ឋានជីវភាពសហគមន៍

_ នាយកដ្ឋានតំបន់បេតិកភណ្ឌ

_ នាយកដ្ឋានទេសចរណ៍ធម្មជាតិ។[6]

➢ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

_ ទទួលខុសត្រូវ និងសម្របសម្រួលកិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុទូទៅ

_ រៀបចំលិខិតរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ

_ គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ក្រសួង

_ គ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ

_ គ្រប់គ្រង និងសម្របសម្រួលការងារលទ្ធកម្មសាធារណៈ

_ គ្រប់គ្រងសម្ភារៈ បរិក្ខា ទ្រព្យសម្បត្តិ និងអចលនទ្រព្យរបស់ក្រសួង

_ ទទួលខុសត្រូវ និងសម្របសម្រួលការរៀបចំផែនការ និងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ក្រសួង ស្របតាមគោលនយោបាយ និងផែនការរបស់រាជរដ្ឋាភិបាល

_ សម្របសម្រួលការរៀបចំសេចក្តីព្រាងនិងចងក្រងរក្សាទុកលិខិតបទដ្ឋានគតិយុត្តនានា ជាអាទិ៍ សេចក្តីសម្រេច ប្រកាស ប្រកាសអន្តរក្រសួង អនុក្រឹត្យ ព្រះរាជក្រឹត្យ ច្បាប់ និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងបរិស្ថាន

_ ផ្តល់យោបល់ផ្នែកច្បាប់លើអត្ថបទ កិច្ចសន្យា កិច្ចព្រមព្រៀង ករណីរឿងក្តី ករណីវិវាទ ដែលពាក់ព័ន្ធនឹងក្រសួង

_ សម្របសម្រួលការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង

_ គ្រប់គ្រងការងារពិធីការរបស់ក្រសួង

_ សម្របសម្រួលជាមួយអគ្គនាយកដ្ឋានដទៃទៀតជាប្រចាំ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រសួង

[6] មាត្រា២៨ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

- គ្រប់គ្រងបណ្ណសារដ្ឋានរបស់ក្រសួង
- គ្រប់គ្រងនិងចាត់ចែងការងារសង្គមកិច្ចសម្រាប់បុគ្គលិក ទាំងក្នុងក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌរបស់ក្រសួង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះដូចខាងក្រោមៈ

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានធនធានមនុស្ស
- នាយកដ្ឋានផែនការ និងថវិកា
- នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានហិរញ្ញវត្ថុនិងគណនេយ្យ។[7]

នៅក្នុងចំណោមតួនាទីរបស់ខ្លួន ក្រសួងបរិស្ថាន ជាអ្នកទទួលខុសត្រូវលើការអភិវឌ្ឍផែនការគ្រប់គ្រងបរិស្ថានថ្នាក់ ជាតិ និងថ្នាក់តំបន់ ក្នុងគោលបំណងដើម្បីកំណត់បញ្ហាប្រឈមផ្នែកបរិស្ថានសំខាន់ៗ និងមធ្យោបាយដើម្បីដោះស្រាយបញ្ហាទាំងនោះ។ មុនពេលចេញសេចក្តីសម្រេចចិត្តណាមួយ ឬការធ្វើសកម្មភាពណាមួយ ដែលទាក់ទងទៅនឹងការអភិរក្ស ការអភិវឌ្ឍការគ្រប់គ្រងឬការប្រើប្រាស់ធនធានធម្មជាតិ ក្រសួងពាក់ព័ន្ធត្រូវតែពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថានជាមុនសិន។ ក្រសួងបរិស្ថាន ក៏មានតួនាទីក្នុង ការត្រួតពិនិត្យ ការរក្សាទុកបញ្ជី និងការស៊ើបអង្កេត ហើយមន្ត្រីបរិស្ថានមានសិទ្ធិចូលទៅក្នុងតំបន់ ដើម្បីត្រួតពិនិត្យករណីដែលអាចកើតមានការបំពុលបរិស្ថាន។

### ១.២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

កិច្ចការការពារបរិស្ថាន និងធនធានធម្មជាតិនៅកម្ពុជា គឺក៏ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មានដែនសមត្ថកិច្ចលើវិស័យកសិកម្ម វិស័យព្រៃឈើ វិស័យជលផល និងការផ្តល់គម្រោងសម្បទានដីសេដ្ឋកិច្ច។ លើសពីនេះទៀត ក្រសួងកសិកម្ម គឺជាអង្គភាពបង្គោលនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងភាពក្លាយជាវាលរហោឋាន។

- **រដ្ឋបាលព្រៃឈើ៖** គ្រប់គ្រងព្រៃឈើ និងសត្វព្រៃ, ធ្វើសារពើភ័ណ្ឌ, ការពារ និងគ្រប់គ្រងធនធានព្រៃឈើ និងការអភិរក្សសត្វព្រៃ។
- **រដ្ឋបាលជលផល៖** ត្រូវបានប្រគល់សិទ្ធិក្នុងការគ្រប់គ្រងធនធានទឹកសាប និងសមុទ្រ និងវារីវប្បកម្ម។

យើងខ្ញុំយកនាយកដ្ឋានពីរមកបកស្រាយ ដែលពាក់ព័ន្ធនឹងកិច្ចការការពារបរិស្ថាន និងធនធានធម្មជាតិនៅកម្ពុជា។

[7] មាត្រា៣៣ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

➢ នាយកដ្ឋានរុក្ខាប្រមាញ់ មានភារកិច្ចដូចខាងក្រោមៈ

_ធ្វើបញ្ជីសារពើភ័ណ្ឌធនធានព្រៃឈើ និងសត្វព្រៃ វាយតម្លៃសក្តានុពលភាព ការបែងចែកប្រភេទ និងតាមដានការវិវឌ្ឍន៍របស់ព្រៃឈើ និងសត្វព្រៃ

_រៀបចំគម្រោង អត្ថបទច្បាប់ លិខិតបទដ្ឋាន បទបញ្ញា សម្រាប់ការពារ និងសម្រាប់គ្រប់គ្រងការធ្វើអាជីវកម្មព្រៃឈើ ការអភិវឌ្ឍន៍សត្វព្រៃ ការប្រមាញ់ និងត្រួតពិនិត្យការអនុវត្តន៍

_ចូលរួមកំណត់វិធានការរក្សាការពារបរិស្ថាន និងរៀបចំកសាងផែនការ គ្រប់គ្រងដែនដីព្រៃឈើ ទីព្រៃបំរុងទុកសម្រាប់ធ្វើជម្រកសត្វព្រៃ តំបន់ការពារធម្មជាតិ តំបន់ដាំព្រៃឈើឡើងវិញ និងកំណត់នយោបាយអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ

_ធ្វើការសិក្សាស្រាវជ្រាវ អំពីវិទ្យាសាស្ត្រវិស័យសត្វព្រៃ និងចងក្រងឯកសារ

_ត្រួតពិនិត្យ និងគ្រប់គ្រងរាល់សកម្មភាពធ្វើអាជីវកម្មផល អនុផលព្រៃឈើ និងរាល់សកម្មភាពធ្វើប្រមាញ់ធនធានសត្វព្រៃ

_ជួយទំនុកបម្រុង លើកទឹកចិត្ត អ្នកផ្តើមគំនិតការពារ និងធ្វើឱ្យកើតឡើងវិញ នូវធនធានព្រៃឈើ និងសត្វព្រៃ ហើយនិងយកចិត្តទុកដាក់ដល់សហគមន៍ព្រៃឈើ

_គ្រប់គ្រង និងអភិវឌ្ឍន៍សួនសត្វ

_ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។[8]

➢ នាយកដ្ឋានជលផល មានភារកិច្ចដូចខាងក្រោមៈ

_ធ្វើបញ្ជីសារពើភ័ណ្ឌធនធានជលផល វាយតម្លៃសក្តានុពលភាព ការបែងចែកប្រភេទ និងតាមដានការវិវត្តរបស់ធនធានជលផល និងវារីវប្បកម្ម

_រៀបចំគម្រោង អត្ថបទច្បាប់ លិខិតបទដ្ឋាន បទបញ្ញា សម្រាប់ការពារ ថៃរក្សា កែលម្អ និងពង្រឹងសណ្តាប់ធ្នាប់ដែននេសាទ និងសម្រាប់គ្រប់គ្រងការធ្វើអាជីវកម្មធនធានជលផលទាំងផ្នែកទឹកសាប និងដែនសមុទ្រ និងត្រួតពិនិត្យការអនុវត្ត

_ចូលរួមកំណត់វិធានការរក្សាការពារបរិស្ថាន និងរៀបចំកសាងផែនការ គ្រប់គ្រងដែននេសាទកន្លែងនេសាទបម្រុងទុក និងកំណត់នយោបាយអភិវឌ្ឍន៍ និងអភិរក្សធនធានជលផល

_ការសិក្សាស្រាវជ្រាវ អំពីវិទ្យាសាស្ត្រវិស័យជលផល និងវារីវប្បកម្ម និងចងក្រងឯកសារ

_ត្រួតពិនិត្យ និងគ្រប់គ្រងរាល់សកម្មភាព ធ្វើអាជីវកម្មធនធានជលផល និងវារីវប្បកម្ម

_ជួយទំនុកបម្រុង លើកទឹកចិត្តដល់អ្នកផ្តើមគំនិតការពារ និងធ្វើឱ្យកើតឡើងវិញ នូវធនធានជលផល និងយកចិត្តទុកដាក់ជំរុញវារីវប្បកម្ម

_ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។[9]

[8] មាត្រា ១៨ ការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ

[9] មាត្រា ១៩ ការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមិទ្ធផល(២០១៣-២០១៧)សម្រេចបានដូចខាងក្រោម៖

- បានបណ្តុះកូនឈើនៅតាមបណ្តាថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើ ថ្នាលបណ្តុះកូនឈើសម្តេចតេជោ បានបណ្តុះចែកជូនប្រជាពលរដ្ឋបាន ៥០៧ ៩៥៨ដើម
- បានអនុវត្តនូវគម្រោងស្រាវជ្រាវដោយប្រើប្រាស់ថវិកាជាតិចំនួន២ គឺគម្រោងពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការអភិរក្ស ស្រាវជ្រាវព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព និងគម្រោងស្តារព្រៃឈើឡើងវិញក្រោយអាជីវកម្មនៅតំបន់បាក់ស្នាខេត្តកំពង់ធំ ក្រៅពីនេះបានអនុវត្តគម្រោងស្រាវជ្រាវសហប្រតិបត្តិការដោយមានការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានាផងដែរ
- រដ្ឋបាលព្រៃឈើបានទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃ
- បានបង្កើតសហគមន៍នេសាទសរុបចំនួន ៥១៦សហគមន៍នៅតាមបណ្តាខេត្តនានា និងបង្កើតតំបន់អភិរក្សនៃកន្លែងនេសាទសហគមន៍នីមួយៗដែលត្រូវការពារ និងគ្រប់គ្រង
- បានគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផល រីកចម្រើនគួរឱ្យកត់សម្គាល់ ដែលជាលទ្ធផលសំខាន់ៗរួមមាន ការសាងសង់វិទ្យាស្ថានស្រាវជ្រាវនិងវារីវប្បកម្ម ការសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ ការសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវនេសាទបឹងទន្លេសាបនិងការរៀបចំបង្កើតវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ។

### ១.៣.ក្រសួងរ៉ែ និងថាមពល

បើយើងក្រឡេកមើលក្រសួងរ៉ែ និងថាមពល ក៏មានតួនាទី អភិរក្ស និងការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។ដោយឡែកចំពោះ ការរុករករ៉ែ ថាមពល ប្រេងនិងឧស្ម័នស្ថិតក្រោមដែនសមត្ថកិច្ចរបស់ ក្រសួងរ៉ែ និងថាមពល។ ក្រសួងនេះ ត្រូវបានប្រគល់សិទ្ធិ ក្នុងការអភិវឌ្ឍ និងគ្រប់គ្រងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការស្តីពីថាមពល ។ បន្ថែមទៀតនោះក្រសួងនេះក៏មានទំនួលខុសត្រូវក្នុងការផ្តល់អាជ្ញាប័ណ្ណរុករករ៉ែ និងការត្រួតពិនិត្យសកម្មភាពរបស់ក្រុមហ៊ុនរុករករ៉ែ។

ក្រសួងរ៉ែ និងថាមពលមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រ លើវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- រៀបចំតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- អនុវត្តផែនការយុទ្ធសាស្ត្រនិងសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិ សំដៅគ្រប់គ្រងនិងអភិវឌ្ឍវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- គ្រប់គ្រង ការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ ការផ្សព្វផ្សាយទិន្នន័យភូគព្ភសាស្ត្រ និងការសិក្សាស្រាវជ្រាវរុករកធនធានរ៉ែ

- គ្រប់គ្រង ការអភិវឌ្ឍ ការធ្វើអាជីវកម្ម ការប្រើប្រាស់ធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ការបន្សុទ្ធ និងការចម្រាញ់រ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែ
- គ្រប់គ្រង ការសិក្សាស្រាវជ្រាវអំពីប្រភពការផលិត ការចែកចាយ និងការប្រើប្រាស់ថាមពល ព្រមទាំងការការពារសុវត្ថិភាពក្នុងវិស័យថាមពល
- គ្រប់គ្រង ការធ្វើផែនការនិងការអភិវឌ្ឍអគ្គិសនី ស្ថានីយផលិតអគ្គិសនី ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី ប្រព័ន្ធចែកចាយអគ្គិសនី និងវាយតម្លៃសក្តានុពលវារីអគ្គិសនីដើម្បីរៀបចំអភិវឌ្ឍន៍ទំនប់វារីណាដែលមានការផលិតថាមពលអគ្គិសនីជាគោលបំណងចម្បង
- គ្រប់គ្រងការងារប្រេងកាតផ្នែកអាប់ស្ទ្រីម(Upstream) និងផ្នែកដោនស្ទ្រីម(Downstream) ដែលរួមមានបុរេសនា ការស្វែងរុករក ការអភិវឌ្ឍនិងផលិតកម្មប្រេងកាត ការធ្វើប្រព្រឹត្តិកម្មប្រេងកាតនិងគីមីប្រេងកាត ការដឹកជញ្ជូននិងចែកចាយ សន្និធិ ការនាំចេញ-នាំចូល និងការធ្វើពាណិជ្ជកម្មប្រេងកាតនិងផលិតផលប្រេងកាត
- លើកកម្ពស់ការការពារសុវត្ថិភាព សុខភាព និងលក្ខខណ្ឌការងារក្នុងវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- លើកកម្ពស់ ការការពារនិងអភិរក្សគុណភាពបរិស្ថាន និងសុខុមាលភាពសង្គម ក្នុងវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- កៀរគរចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី។[10]

ក្រសួងរ៉ែនិងថាមពលមានសមិទ្ធផលសម្រេចបាន(២០១៣-២០១៧)ដូចខាងក្រោម៖

- បានរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យថាមពលអគ្គិសនី ដើម្បីទាក់ទាញឱ្យមានការចូលរួមពីវិស័យឯកជននៅក្នុងការវិនិយោគលើវិស័យអគ្គិសនី
- ក្រសួងបានយកចិត្តទុកដាក់ជំរុញការចូលរួមអភិវឌ្ឍប្រភពអគ្គិសនីស្អាតផងដែរ ដូចជាប្រភពអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ
- វារីអគ្គិសនី និងរោងចក្រអគ្គិសនីដុតធ្យូងថ្មដែលបានដាក់ឱ្យដំណើរការរួមមាន វារីអគ្គិសនីគីរីរម្យ១ វារីអគ្គិសនីកំចាយ អគ្គិសនីគីរីរម្យ៣ វារីអគ្គិសនីស្ទឹងអាតៃ វារីអគ្គិសនីឬស្សីជ្រុំក្រោម វារីអគ្គិសនីស្ទឹងតាតៃ រោងចក្រអគ្គិសនីដុតធ្យូងថ្មខេត្តព្រះសីហនុ រោងចក្រអគ្គិសនីដុតធ្យូងថ្មខេត្តកណ្តាល និងគម្រោងវារីអគ្គិសនីសេសានក្រោម២

[10] មាត្រា៥ អនុក្រឹត្យស្តីពីការរៀបចំនឹងប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

_ដើម្បីពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យរ៉ែនៅឆ្នាំ២០១៦ អនុក្រឹត្យស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈ និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មរ៉ែលោហៈ លេខ៧២ អនក្រ.បក. របស់រាជរដ្ឋាភិបាលត្រូវបានអនុម័ត និងចូលជាធរមាន

_ក្រសួងបានខិតខំអភិវឌ្ឍវិស័យប្រេងកាត ដោយឱ្យស្ថានីយប្រេងនិងឧស្ម័នឥន្ធនៈដំណើរការតាមបច្ចេកទេសសុវត្ថិភាព និងនីតិវិធីនៃការគ្រប់គ្រងរបស់ក្រសួងរ៉ែ និងថាមពល រួមទាំងកំណត់តម្លៃលក់រាយប្រេងឥន្ធនៈតាមតម្លៃទីផ្សារអន្តរជាតិដោយមានរូបមន្តជាក់លាក់។

## ផ្នែកទី២ : ស្ថាប័នគាំពារបរិស្ថាន និងធនធានធម្មជាតិ

### ២.១. ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពគឺជាស្ថាប័នរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីសម្របសម្រួលការងារថ្នាក់ក្រសួងដោយទទួលបន្ទុករៀបចំគោលនយោបាយ ដែលត្រូវបង្កើតឡើងដោយការរួមបញ្ចូលគ្នានៃស្ថាប័នអន្តរក្រសួង មានចំនួន៤គឺៈ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គណៈកម្មាធិការជាតិជីវសុវត្ថិភាព និងគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ និងត្រួតពិនិត្យការអភិវឌ្ឍដែលផ្តែកលើសរសរស្តម្ភចំនួនបួនគឺ បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌។[11] ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ ហើយមានទីស្នាក់ការនៅក្រសួងបរិស្ថាន។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។[12]

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពមានតួនាទីភារកិច្ចដូចខាងក្រោមៈ

_រៀបចំ ណែនាំ សម្របសម្រួលអនុវត្ត និងវាយតម្លៃគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោង ពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព

_លើកកម្ពស់ការបញ្ជ្រាបការអភិវឌ្ឍដោយចីរភាពទៅក្នុងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងពាក់ព័ន្ធនានា ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

_កៀរគរធនធានសម្រាប់អនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោង ពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព

_កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធផ្សេងទៀត សំដៅគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព

_ជំរុញនិងលើកកម្ពស់ការសិក្សាស្រាវជ្រាវ ការអប់រំ ការបណ្តុះបណ្តាល ការផ្លាស់ប្តូរបច្ចេកវិទ្យា និងការផ្សព្វផ្សាយពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព

[11] មាត្រា១ ព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

[12] មាត្រា១០ ព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- លើកយោបល់ ជំហរ និងយុទ្ធសាស្ត្រជាតិ សម្រាប់ចូលរួមក្នុងកិច្ចព្រមព្រៀង កិច្ចប្រជុំ និងការចរចាអន្តរជាតិនានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- ពិនិត្យនិងអនុម័តរបាយការណ៍ផ្លូវការនានារបស់ជាតិ ដែលតម្រូវឱ្យរៀបចំ នៅក្រោមកិច្ចព្រមព្រៀងបរិស្ថានពហុភាគីនានា ដែលកម្ពុជាជាសមាជិក
- គ្រប់គ្រងព័ត៌មាននិងការប្រាស្រ័យទាក់ទងពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍ដោយចីរភាព
- ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារសេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។[13]

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបានសម្រេចសមទ្ធិផលសំខាន់ ដូចជា៖

➢ ការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតង

- ការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រទីក្រុងបៃតងសម្រាប់រាជធានីភ្នំពេញ ដោយរួមបញ្ចូលទាំងគម្រោងវិនិយោគទាំង៤៨ និងផែនការយុទ្ធសាស្ត្រទីប្រជុំជនបៃតងដំណាក់កាលទី២សម្រាប់ទីក្រុងចំនួន៧ទៀត
- ការរៀបចំកម្មវិធីតម្រង់ទិសគោលនយោបាយ ដើម្បីបញ្ជ្រាបការអភិវឌ្ឍបៃតងនៅក្នុងយុទ្ធសាស្ត្រចតុកោណជំហានបន្ទាប់ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣។

➢ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

- ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ
- ការសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ ទៅក្នុងសារាចរណែនាំស្តីពីការរៀបចំផែនការ យុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧និងបានគាំទ្រក្រសួងចំនួនបួន(ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសុខាភិបាល និងក្រសួងបរិស្ថាន) ដើម្បីដាក់បញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងសំណើផែនការថវិការបស់ខ្លួន។

➢ ជីវៈចម្រុះ

- តំបន់ការពារធម្មជាតិ និងរបៀបអភិរក្សជីវៈចម្រុះត្រូវបានបង្កើត និងពង្រីក លើផ្ទៃដីលើសពី៧លានហិកតា ឬស្មើនឹង៤១%នៃផ្ទៃប្រទេស លើសគោលដៅជីវៈចម្រុះសាកលដែលកំណត់ត្រឹម១៧%
- បានចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវលើធនធានពន្ធុរបស់កម្ពុជា ដោយផ្តោតជាជំហានដំបូងលើសត្វល្អិតនិងប្រភេទរុក្ខជាតិដែលមានតម្លៃទីផ្សារ ក្រោមក្របខណ្ឌពិធីសារណាហ្គូយ៉ា។

➢ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

[13] មាត្រា៣ ព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

_ បានចុះហត្ថលេខាលើ កិច្ចព្រមព្រៀង និងអនុស្សរណ: សរុបចំនួន៥ជាមួយរុស្ស៊ីនិងចិន ដើម្បីសហប្រតិបត្តិ ការក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោល បំណងសន្តិភាព។

## ២.២. អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្ស និងធនធានធម្មជាតិ

អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ(IUCN) គឺជាអង្គការអន្តរជាតិមួយដែលបានបង្កើតឡើងនៅឆ្នាំ ១៩៤៨ ដែលមានការិយាល័យធំនៅក្រុង Gland ប្រទេសស្វីស ដែលបង្កើតឡើងក្នុងគោលបំណង ជួយឱ្យពិភពលោករកដំណោះស្រាយជាក់ស្តែងទៅនឹងបរិស្ថាន និងការអភិរក្សបញ្ហាប្រឈមបន្ទាន់បំផុតរបស់យើង។ ការងាររបស់អង្គការផ្តោតសំខាន់លើការឱ្យតម្លៃ និងការអភិរក្សធម្មជាតិដើម្បីធានាប្រសិទ្ធិភាព និងសមភាពអភិបាលកិច្ចនៃការប្រើប្រាស់របស់ខ្លួន និងការដាក់ពង្រាយដំណោះស្រាយធម្មជាតិដែលមានមូលដ្ឋានទៅ នឹងបញ្ហាប្រឈមជាសកលនៅក្នុងអាកាសធាតុម្ហូបអាហារ និងការអភិវឌ្ឍ។ មួយវិញទៀតអង្គការ(IUCN) ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រគាំទ្រ គ្រប់គ្រងគម្រោងវាលទាំងអស់នៅលើពិភពលោកហើយនាំមកនូវ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការសហប្រជាជាតិ និងក្រុមហ៊ុនរួមគ្នាដើម្បីធ្វើការអភិវឌ្ឍគោលនយោបាយច្បាប់ និងការអនុវត្តល្អបំផុត។ អង្គការ(IUCN)ដែលជាអង្គការបរិស្ថានសាកលចំណាស់ជាងគេបំផុតរបស់ពិភពលោក ដែលបានប្រមូលផ្តុំរដ្ឋចំនួន ៨៣ ភ្នាក់ងាររដ្ឋបាលចំនួន ១០៨ អង្គការជាតិចំនួន ៧៦៦ អង្គការអន្តរជាតិចំនួន ៨១ និងអ្នកជំនាញវិទ្យាសាស្ត្រប្រហែលជាង ១ម៉ឺននាក់ មកពីបណ្តាប្រទេសនៅជុំវិញពិភពលោក។

ក្រសួងបរិស្ថាន និងអង្គការសហភាពអន្តរជាតិ(IUCN)បានព្រមព្រៀងគ្នា សហប្រតិបត្តិការជាមួយគ្នា ដើម្បីអភិរក្សធនធានធម្មជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅកម្ពុជា។ ពិធីចុះហត្ថលេខារួមគ្នាលើអនុស្សរណៈយោគយល់គ្នា បានប្រព្រឹត្តទៅនាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ នាទីស្តីការក្រសួងបរិស្ថានដោយលោកស្រី Aban Marker Kabraji នាយកអង្គការ IUCN ប្រចាំតំបន់អាស៊ី និង**ឯកឧត្តម ស៊ូ ខនបូទ្ធីគុណា** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

អនុស្សារណៈព្រមព្រៀងគ្នានេះផ្តោតជាសំខាន់លើការអនុវត្តរួមមាន:

១-ការអភិរក្សតំបន់ដីសើមទឹកសាបសមុទ្រ

២-អភិបាលកិច្ចតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ

៣-ការបន្សាំដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ី ការកាត់បន្ថយ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ

៤-កិច្ចសហប្រតិបត្តិការឆ្លងដែនស្តីពីការអភិរក្សសត្វព្រៃ និងរុក្ខជាតិ និងការគ្រប់គ្រងទន្លេ

៥-ការរៀបចំអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រនៃការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ

៦-ការសិក្សាស្រាវជ្រាវ សត្វព្រៃ និងប្រភេទជីវៈចម្រុះដទៃទៀត។

នៅក្នុងអនុសារណៈយោគយល់គ្នារវាងក្រសួងបរិស្ថាន និងអង្គការ IUCN មានរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០ដើម្បីសម្រេចកសាងភាពធន់របស់សហគមន៍ នឹងការ

ប្រែប្រួលអាកាសធាតុនៅតំបន់រ៉ាមសារចំនួន៣ និងជួយក្រសួងបរិស្ថាន ក្នុងការកំណត់ និងបង្កើត តំបន់រ៉ាមសារ និងតំបន់ការពារធម្មជាតិដីកោគថ្មីបន្ថែមទៀត ពិសេសកិច្ចសហការជួយគាំទ្រដល់នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប ក្នុងការរៀបចំបង្កើតតំបន់ភ្នំថ្មកំបោរ ជាតំបន់ការពាធម្មជាតិផងដែរ។

➢ សកម្មភាពនានារបស់អង្គការ(IUCN)ជាមួយដៃគូពាក់ព័ន្ធថ្នាក់ជាតិដូចតទៅៈ

_នាយកដ្ឋានអភិរក្សសមុទ្រ និងតំបន់ឆ្នេរ និងអង្គការ (IUCN) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីសារៈសំខាន់ធនធានសមុទ្រ តំបន់ឆ្នេរ និងការកំណត់ព្រំប្រទល់ឧទ្យានជាតិសមុទ្រ កោះរុង ដែលមានអ្នកចូលរួមពីស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ តំណាងសហគមន៍នេសាទមកពីសង្កាត់កោះរុង និងកោះរុងសន្លឹម។

_អាជ្ញាធរទន្លេសាបបានជួបពិភាក្សាជាមួយតំណាងអង្គការ (IUCN) ក្នុងគោលបំណងធ្វើគំនិតផ្តួចផ្តើមរៀបចំគម្រោងសហប្រតិបត្តិការលើការសិក្សា និងសំអាតសំណល់ឧបករណ៍សាច់មងចាស់ៗ ដែលបោះបង់ចោលនៅក្នុងប្រព័ន្ធអេកូឡូស៊ីជុំវិញបឹងទន្លេសាប

_អង្គការអន្តរជាតិអភិរក្សធនធានធម្មជាតិ (IUCN) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទៅ នឹងសហគមន៍តំបន់ឆ្នេរក្នុងប្រទេសកម្ពុជា និងប្រទេសថៃ សិក្ខាកាមគឺជាអ្នកសារព័ត៌មានកម្ពុជាដែលមកពីខាងកាសែតភ្នំពេញប៉ុស្តិ៍ និងទូរទស្សន៍CNC ចំណែកឯខាងភាគីថៃវិញនោះគឺមានមកពីទីភ្នាក់ងាផ្សាយព័ត៌មានថៃ

_ក្រោមកិច្ចសហការរវាងសាលាខេត្តកំពត និងអង្គការ (IUCN) នៅកម្ពុជាបានលើឡើងក្រោមការផ្តល់មូលនិធិករបស់សហភាពអឺរ៉ុបបានបើសិក្ខាសាលាមួយ ស្តីអំពីចាប់ផ្តើមអនុវត្តន៍គម្រោងស្តីពីការរៀបចំកំណត់បែងចែក ការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ។

មួយវិញទៀតសត្វ ឬរុក្ខជាតិដែលត្រូវចាត់ក្នុងបញ្ជីក្រហមនៃអង្គការ (IUCN) គឺសុទ្ធសឹងតែជាប្រភេទរុក្ខជាតិ និងសត្វ ដែលជាប្រភេទកម្រ និង ប្រភេទដែលឈានទៅរកការផុតពូជដែលទទួលបានការវាយតម្លៃជាសកលពីឋានៈរបស់វា។ យ៉ាងណាមិញ បើយើងក្រឡេកមើលដែនជម្រកសត្វព្រៃកែវសីមា ផ្តល់ជាទីជម្រកធម្មជាតិដល់សត្វព្រៃ និងរុក្ខាជាតិជាង៦០ប្រភេទស្ថិតក្នុងបញ្ជីក្រហមរបស់អង្គការ(IUCN) ដែលជាប្រភេទរងការគំរាមកំហែង ឈានទៅរកការផុតពូជ។

# ជំពូកទី២

# សកម្មភាពផ្សេងៗ ក្នុងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ

## ផ្នែកទី១ : ការគាំពារបរិស្ថាន

អគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន ជាអង្គភាពស្ថិតក្រោមឱវាទក្រសួងដែលមានតួនាទី និងភារកិច្ចស្នូលក្នុងការងារគ្រប់គ្រង និងសម្របសម្រួលកិច្ចគាំពារបរិស្ថាន។ ក្នុងអគ្គនាយកដ្ឋាននោះមាន នាយកដ្ឋានចំនួន៥ (នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់និងសម្លេង, នាយកដ្ឋានគ្រប់គ្រងគុណភាពទឹក, នាយកដ្ឋានគ្រប់គ្រងសំណល់រឹង, នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់, នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន) ក្នុងនាយកដ្ឋាននីមួយៗបានសម្រេចសមិទ្ធផលដូចខាងក្រោម៖

### ១.១. ការគ្រប់គ្រងគុណភាពខ្យល់ និងសម្លេង

ការគ្រប់គ្រងគុណភាពខ្យល់ និងសម្លេងបានសម្រេចសមិទ្ធផលដូចខាងក្រោម៖

_បានរៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការការពារគុណភាពខ្យល់ ស្តង់ដារគុណភាពខ្យល់បរិយាកាស និងខ្យល់ក្នុងអគារ ស្តង់ដារនៃការបញ្ចេញផ្សែង ចំហាយ ឧស្ម័ន ភាគល្អិតនិចល សំឡេងរំញ័រ ពីប្រភពចល័តនិងអចល័ត និងស្តង់ដារសារធាតុបំពុលបរិស្ថានដែលមានផ្ទុកក្នុងឥន្ធនៈហ្វូស៊ីល

_បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំបច្ចេកទេស ស្តីពីការត្រួតពិនិត្យគុណភាពខ្យល់ និងសម្លេងនៅតាមរោងចក្រ និងផលិតកម្មដែលមានសក្តានុពលបំពុលខ្យល់ និងសម្លេងខ្ពស់

_បានបំពាក់ឧបករណ៍ស្វ័យប្រវត្តិកម្ម (ឧបករណ៍ត្រួតពិនិត្យ PM2.5) ដើម្បីតាមដានស្ថានភាពគុណភាពខ្យល់ នៅតាមទីក្រុងគោលដៅធំៗសម្រាប់វាយតម្លៃពីកម្រិតគ្រោះថ្នាក់បានទាន់ពេល

_ចុះយកសំណាកខ្យល់តាមខេត្តគោលដៅ បាត់ដំបង សៀមរាប និងខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ លើប៉ារ៉ាម៉ែត្រ CO,$SO_2$,$NO_2$ PM-10 NនិងTSP

_បានគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់ និងវាយតម្លៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈពីស្ថានភាពគុណភាព និងការបំពុលខ្យល់នៅទូទាំងប្រទេស។

### ១.២. ការគ្រប់គ្រងគុណភាពទឹក

ការគ្រប់គ្រងគុណភាពទឹកបានសម្រេចសមិទ្ធផលដូចខាងក្រោម៖

_បានរៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការការពារគុណភាពទឹក ស្តង់ដារគុណភាពទឹកនៃតំបន់ សាធារណៈ និងស្តង់ដារនៃការបញ្ចេញទឹកល្អនិងសំណល់រាវ

_បានបង្កើតស្ថានីយ៍នៅទន្លេចតុមុខ(រាជធានីភ្នំពេញ) និងបំពាក់ឧបករណ៍ស្វ័យប្រវត្តិកម្ម ដើម្បីតាមដានគុណភាពទឹក និងព្យាករណ៍ពីកម្រិតគ្រោះថ្នាក់បានទាន់ពេល

_តាមដានគុណភាពទឹកសាធារណៈជាប្រចាំចំនួន១២ខេត្តគោលដៅ និងទឹកល្អចំនួន៥ខេត្តគោលដៅ

_ដាក់ឱ្យដំណើរការសាកល្បង ម៉ាស៊ីនសម្អាតទឹកកខ្វក់ចល័ត សមត្ថភាព១០០ម$^3$/ថ្ងៃ នៅឆ្នេរកែប

_បាននិងកំពុងសហការជាមួយក្រសួង ស្ថាប័នដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន ដើម្បីស្វែងរកដំណោះស្រាយបញ្ហាល្ងរំដោះទឹកភ្លៀង និងលូបង្ហូរទឹកសម្អុយនៅតាមទីប្រជុំជន ជាពិសេសនៅតាមបណ្តាខេត្តក្នុងតំបន់ឆ្នេរសមុទ្រ និងរាជធានីភ្នំពេញ

_បានចូលរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្កើនការអប់រំ និងផ្សព្វផ្សាយដល់សាធារណជនអំពីសេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងគោលដៅការពារគុណភាពបរិស្ថាន។

### ១.៣. ការគ្រប់គ្រងសំណល់រឹង

ការគ្រប់គ្រងសំណល់រឹងបានសម្រេចសមិទ្ធផលដូចខាងក្រោម៖

_បានរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការនិងថវិកា លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង

_បានរៀបចំសេចក្តីណែនាំ និងផ្សព្វផ្សាយជូនសាធារណជនអំពីការអនុវត្តកម្មវិធីញែកសំណល់រឹងនៅនឹងប្រភព ការចូលរួមប្រើប្រាស់សេវាកម្មប្រមូលនិងដឹកជញ្ជូន និងការអនុវត្តគោលការណ៍ កាត់បន្ថយការបង្កើត បង្កើនការប្រើប្រាស់ឡើងវិញ និងបង្កើនការកែច្នៃដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ

_បានសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តការប្រើប្រាស់ «កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន» សម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងនៅតាមទីប្រជុំជន ក្រុងនៅទូទាំងប្រទេស

_បានចេញនូវសារាចរណែនាំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត និងប្រើប្រាស់ «កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន» សម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹង រាវ នៅតាមទីប្រជុំជនក្រុងនៅទូទាំងប្រទេស

_បាននិងកំពុងសហការជាមួយក្រសួងមហាផ្ទៃ ក្នុងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំណល់រឹង នៅតាមបណ្តាទីប្រជុំជន ក្រុង ស្រុក ខណ្ឌ ដោយតម្រូវឱ្យមន្ទីរបរិស្ថានខិតខំបំពេញភារកិច្ច និងចាត់វិធានការតាមការចាំបាច់ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ នៅក្នុងមូលដ្ឋានរបស់ខ្លួន

- បាននិងកំពុងសហការកែសម្រួលការគ្រប់គ្រងសំរាមសំណល់រឹងក្នុងរាជធានីភ្នំពេញ តាមរយៈការសិក្សា និងពិនិត្យឡើងវិញនូវកិច្ចសន្យាប្រតិបត្តិការប្រមូល និងដឹកជញ្ជូនសំរាម និងពិនិត្យលទ្ធភាពបែងចែកតំបន់គ្រប់គ្រងនៅតាមបណ្ដាខណ្ឌ ដើម្បីពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងសំរាម ក្នុងរាជធានីភ្នំពេញ
- បានរៀបចំគោលការណ៍ណែនាំ និងត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោលប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្ដាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព
- បានរៀបចំតាក់តែងគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងផ្ដល់ជំនាញបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពនូវវិធានការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក រួមទាំងធ្វើការអប់រំ និងយុទ្ធនាការផ្សព្វផ្សាយគ្រប់រូបភាពជូនដល់សាធារជនឱ្យយល់ដឹងពីផលប៉ះពាល់លើការប្រើប្រាស់ និងការបោះចោលសំណល់ថង់ប្លាស្ទិក
- បានតាមដាន និងផ្សព្វផ្សាយលទ្ធផលអនុវត្តការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកថ្នាក់ជាតិប្រចាំឆ្នាំ និងលើកទិសដៅអនុវត្តឆ្នាំបន្តបន្ទាប់ ហើយរៀបយន្តការលើកសរសើរ និងជូនរង្វាន់ដល់បុគ្គល ឬអង្គភាពដែលមានស្នាដៃលើការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងការកែច្នៃសំណល់ប្លាស្ទិកជារៀងរាល់ឆ្នាំ រួមទាំងផ្ដល់នូវព័ត៌មានជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីហានិភ័យពាក់ព័ន្ធនឹងការនាំចូល និងការចែកចាយថង់ប្លាស្ទិក ដើម្បីជាមូលដ្ឋានពង្រឹងប្រសិទ្ធភាពគ្រប់គ្រងមុខទំនិញនេះនៅមាត់ច្រកព្រំដែន
- ក្រសួងបរិស្ថានបានសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងគោលបំណងដើម្បីចូលរួមថែរក្សាបរិស្ថាន ដោយតម្រូវឱ្យហាងទំនិញគិតកម្រៃបន្ថែមពីអតិថិជនបែបនេះមិនមែនជាការធ្វើអាជីវកម្មដើម្បីរកចំណូលនោះទេ តែជាការពញ្ញាក់ស្មារតី ក៏ដូចជា ការអប់រំដល់ប្រជាពលរដ្ឋឱ្យគិតគូពីបញ្ហាបរិស្ថានតាមរយៈការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក។

### ១.៤. ការគ្រប់គ្រងសារធាតុគ្រោះថ្នាក់

ការគ្រប់គ្រងសារធាតុគ្រោះថ្នាក់បានសម្រេចសមិទ្ធផលដូចខាងក្រោម៖

- បានរៀបចំសេចក្ដីព្រាងគោល នយោបាយ ផែនការ និងថវិកា លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការ ត្រួតពិនិត្យលើដំណើរការគ្រប់គ្រង កែច្នៃកម្ទេចចោល និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់ រួមទាំងកាំរស្មី វិទ្យុសកម្ម និងអេឡិចត្រូម៉ាញ៉េទិច និងសំណល់គ្រោះថ្នាក់ និងការកំណត់អំពីប្រភេទ និងចំណាត់ថ្នាក់នៃសារធាតុគ្រោះថ្នាក់ និងសំណល់គ្រោះថ្នាក់
- បានរៀបចំគោលការណ៍ណែនាំបច្ចេកទេស សម្រាប់ការគ្រប់គ្រងប្រកបដោយសុវត្ថិភាព នូវសារធាតុគ្រោះថ្នាក់ ដើម្បីធានាសុខភាពសាធារណៈ និងបរិស្ថាន រៀបចំស្តង់ដារបច្ចេកទេស និងត្រួតពិនិត្យលើប្រតិបត្តិការសេវាកម្មប្រមូល ដឹកជញ្ជូន កែច្នៃ ការធ្វើប្រព្រឹត្តកម្មនិងទីលានទុកដាក់សំណល់គ្រោះថ្នាក់ជាពិសេសសម្របសម្រួលជាមួយស្ថាប័ន ឬអង្គភាព

ពាក់ព័ន្ធក្នុងការជម្រុញការរៀបចំផែនការសកម្មភាពឆ្លើយតប និងករណីគ្រោះឧបទ្ទវហេតុនៃការឆេះ ផ្ទុះ ការកំពប់ ការលេចធ្លាយសារធាតុគ្រោះថ្នាក់ ឬសំណល់គ្រោះថ្នាក់

_បានរៀបចំរបាយការណ៍ពីកម្រិតនៃការសាយភាយជាតិពុលនៃសារធាតុគ្រោះថ្នាក់ឬសំណល់គ្រោះថ្នាក់ទៅក្នុងបរិស្ថាន និងអំពីផលប៉ះពាល់ដល់សុខភាពសាធារណៈ។

## ១.៥. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បានសម្រេចសមិទ្ធផលដូចខាងក្រោមៈ

_បានរៀបចំសេចក្តីព្រាងគោល នយោបាយ ផែនការ និងថវិកា លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

_បានរៀបចំឯកសារស្តីពីគោលការណ៍ណែនាំ និងលក្ខណៈ វិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមហ៊ុន ដែលស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ជំរុញការបង់មូលនិធិទាយជួទានបរិស្ថាន និងមូលនិធិបរិស្ថាន និងសង្គម

_សម្របសម្រួល ជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីចុះអង្កេត តាមដាន និងពង្រឹងការអនុវត្តផែនការគ្រប់គ្រង បរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

_បានត្រួតពិនិត្យ វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ទៅលើគម្រោងវិនិយោគសាធារណៈ និងឯកជន ដោយមានការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

# ផ្នែកទី២ : ការការពារ និងអភិរក្សធនធានធម្មជាតិ

អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ជាអង្គការស្ថិតក្រោមឱវាទក្រសួងបរិស្ថាន ដែលមានតួនាទីនិងភារកិច្ចស្នូល ក្នុងការគ្រប់គ្រងនិងសម្របសម្រួលការងារអភិរក្សជីវចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិ ឱ្យបានសមស្រប។មាននាយកដ្ឋានចំនួន៥ (នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ, នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប, នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប, នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប, នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ) ក្នុងនាយកដ្ឋាននីមួយៗបានសម្រេចនូវសមិទ្ធផលដូចជាៈ

## ២.១. ការអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ

ការអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ បានសម្រេចសមិទ្ធផលដូចខាងក្រោមៈ

_រៀបចំសេចក្តីព្រាង គោលនយោបាយ ផែនការ និងថវិកា លិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ដីគោកខាងកើតទន្លេមេគង្គ

_រៀបចំការកំណត់ព្រំប្រទល់ ការកំណត់តំបន់គ្រប់គ្រង និងការធ្វើផែនទីសិក្សាស្រាវជ្រាវ និងរៀបចំទិន្នន័យប្រភេទសត្វ និងរុក្ខជាតិដែលកម្រងាយរងគ្រោះ កំពុងរងគ្រោះ និង

ជិតផុតពូជ ក៏ដូចជារៀបចំផែនការទប់សស្កាត់ភ្លើងឆេះព្រៃ បង្រ្កាបបទល្មើសធនធានធម្មជាតិនៅក្នុងតំបន់ ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ

_បោះបង្គោលចំនួន៥០០នៅដែនជម្រកសត្វព្រៃភ្នំព្រេចស្រែពក និងកែរសីមា

_ដាំកូនឈើចំនួន២០០០ដើម និងស្លាកអប់រំបរិស្ថាន២

_ចុះសិក្សាស្រាវជ្រាវប្រមូលទិន្នន័យជម្រុះទីតាំងសសរស្តម្ភក្នុងខេត្ត(១លើក) និងសិក្ខាសាលាថ្នាក់ជាតិ(១លើក)ស្តីពីការដាក់ទីតាំងសសរស្តម្ភជាតំបន់ការពារធម្មជាតិ

_កិច្ចប្រជុំត្រួតពិនិត្យការងាររវាងនាយកដ្ឋាននិងមន្ទីរបរិស្ថាន២ដងក្នុង/ឆ្នាំ

_កិច្ចប្រជុំរវាងអ្នកពាក់ព័ន្ធស្តីការពង្រឹងការគ្រប់គ្រងនៅដែនជម្រកសត្វព្រៃសៀមរាមប៉ាងខាងលិចនិងអូរយ៉ាដាវ។

## ២.២. ការអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប

ការអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងទន្លេសាបបានសម្រេចសមិទ្ធផលដូចខាងក្រោមៈ

_រៀបចំសេចក្តីព្រាង គោលនយោបាយ ផែនការ និងថវិកា លិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ដីគោកខាងត្បូងបឹងទន្លេសាប

_រៀបចំកំណត់ព្រំប្រទល់ ការកំណត់តំបន់គ្រប់គ្រង និងការធ្វើផែនទីសិក្សាស្រាវជ្រាវ និងរៀបចំទិន្នន័យប្រភេទសត្វ និងរុក្ខជាតិដែលកម្រងាយរងគ្រោះ កំពុងរងគ្រោះ និងជិតផុតពូជ អនុវត្តការងារ ការពារអភិរក្សនិងស្តារធនធានធម្មជាតិ ហើយក៏ដូចជារៀបចំផែនការទប់ស្កាត់ភ្លើងឆេះព្រៃ បង្រ្កាបបទល្មើសធនធានធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាបឱ្យមាននិរន្តភាព

